២-១៤.០៣.១១.៣៣២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ...សហវ.

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០១១

## គោរពជូន
## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម

**កម្មវត្ថុ:** សំណើសុំគោលការណ៍ចំណាយថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» ជូននាយកដ្ឋានវិស្វកម្ម នៃក្រសួងធនធានទឹក និងឧតុនិយម ចំនួន ២ ៩៣០ ៦៩៨ ២៥៦ រៀល សម្រាប់ការងារស្តារប្រឡាយ និងសាងសង់សំណង់សិល្បការលើប្រឡាយរងព្រៃខ្លុង ស្ថិតក្នុងស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

**យោង:** - ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១១ លើលិខិតលេខ ៧៩១២ សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

- លិខិតលេខ ០៧៩ ធទឧ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១១ របស់ក្រសួងធនធានទឹកនិងឧតុនិយម ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ សូមជម្រាបឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមផ្តល់ជានាចំណាយជូនចំនួន ២ ៨៦៧ ០០០ ០០០រៀល(ពីរពាន់ប្រាំបីរយហុកសិបប្រាំពីរលានរៀលគត់) ដោយប្រើប្រាស់ឥណទានថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» សម្រាប់ឲ្យនាយកដ្ឋានវិស្វកម្មនៃក្រសួងធនធានទឹកនិងឧតុនិយម អនុវត្តការងារស្តារប្រឡាយ និងសាងសង់សំណង់សិល្បការលើប្រឡាយរងព្រៃខ្លុង ស្ថិតក្នុងស្រុកគងពិសី ខេត្តកំពង់ស្ពឺ រួមមាន៖

| | |
|---|---|
| -ស្តារប្រឡាយរងខ្សែទី ១ | ប្រវែង ៦.២០០ម |
| -ស្តារប្រឡាយរងខ្សែទី ២ | ប្រវែង ១.០០០ម |
| -សាងសង់សំណង់លូមូលដោះទឹកទ្វារមួយ លើប្រឡាយរងខ្សែទី ១ | ចំនួន ០៥កន្លែង |
| -សាងសង់សំណង់លូជ្រុងស្ទាក់ទឹកទ្វារមួយ លើប្រឡាយរងខ្សែទី ១ | ចំនួន ០៦កន្លែង |
| -សាងសង់សំណង់លូជ្រុងឆ្លងកាត់ផ្លូវ លើប្រឡាយរងខ្សែទី ១ | ចំនួន ០៤កន្លែង |
| -សាងសង់សំណង់លូមូលដោះទឹកទ្វារមួយ លើប្រឡាយរងខ្សែទី ២ | ចំនួន ០១កន្លែង |
| -សាងសង់សំណង់លូជ្រុងស្ទាក់ទឹកទ្វារមួយ លើប្រឡាយរងខ្សែទី ២ | ចំនួន ០៣កន្លែង |

សេចក្តីដូចបានជម្រាបខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងធនធានទឹកនិងឧតុនិយម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សាលាខេត្តកំពង់ស្ពឺ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ស្ពឺ
- ឯកសារ-កាលប្បវត្តិ